**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២៤

នៅក្នុងខែមិថុនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភាបាន៖

- អញ្ជើញចូលក្រាបថ្វាយបង្គំគាល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះបរមរាជវាំង។
- ប្រគេនចង្ហាន់ និងទេយ្យវត្ថុ ថ្វាយ**សម្តេចព្រះមហាសុមេធាធិបតី កិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត** សម្តេចព្រះមហាសង្ឃរាជស្តីទី នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តបទុមវតីរាជវរារាម រាជធានីភ្នំពេញ និង
- អនុញ្ញាតឱ្យលោកជំទាវអ្នកឧកញ៉ា **ម៉ៅ ចំណាន** ប្រធានសមាគមសិល្បករខ្មែរ និងគណៈប្រតិភូចូលជួបសម្តែងគារវកិច្ច។

❖ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា, ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី២ព្រឹទ្ធសភា ព្រមទាំងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តបទុមវតីរាជវរារាម រាជធានីភ្នំពេញ។

❖ ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភាបាន៖

- អញ្ជើញជាអធិបតីដឹកនាំប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ដើម្បីពិនិត្យ និង សម្រេចការងារមួយចំនួនរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅវិមានព្រឹទ្ធសភា។
- អញ្ជើញជាអធិបតីបិទសិក្ខាសាលាស្តីពី "កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" របស់រាជរដ្ឋាភិបាលជូនតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា នៅសណ្ឋាគារសុខាភ្នំពេញ។
- អញ្ជើញជាអធិបតីក្នុងពិធីប្រកាសផ្ទេរ និងចូលកាន់តំណែងអគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ, អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ និងកិច្ចប្រជុំបូកសរុបលទ្ធផលការងារ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៤ នៅសាលបណ្ណាល័យព្រឹទ្ធសភា។
- អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីអបអរសាទរខួបគម្រប់១០ឆ្នាំ របស់បណ្ឌិត្យសភា បច្ចេកវិទ្យា ឌីជីថលកម្ពុជា (CADT) នៅមជ្ឈមណ្ឌលបណ្ឌិត្យសភាបច្ចេកវិទ្យា ឌីជីថល កម្ពុជា។
- អញ្ជើញនាំយកទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ និងតាជីយាយជីចាស់ជរា នៅវត្តជ្រោយឧត្តម ស្ថិតក្នុងភូមិព្រៃឈ្មោះ ឃុំព្រែកតាសរ ស្រុកពោធិ៍រៀង ខេត្តព្រៃវែង និង
- អញ្ជើញដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធសពលោក **ងិន ជីវ៉ូ** ចៅសង្កាត់ព្រែកប្រា នៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និងសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ឯម ជា** ដែលត្រូវជាម្តាយក្មេករបស់ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា នៅគេហដ្ឋាននៃសព ស្ថិតក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ។

❖ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី២ព្រឹទ្ធសភាបាន៖

- អញ្ជើញដឹកនាំកិច្ចប្រជុំការងារស្តីពី ការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សម្រាប់នីតិកាលទី៥ នៅបន្ទប់ប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា។
- អញ្ជើញជាអធិបតីក្នុងពិធីប្រកាសផ្ទេរ និងចូលកាន់តំណែងអគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ, អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ និងកិច្ចប្រជុំបូកសរុបលទ្ធផលការងារ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា នៅសាល បណ្ណាល័យព្រឹទ្ធសភា។

- អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ចំនួន ២ខ្នង មាន ១២បន្ទប់ និងសមិទ្ធផលនានា នៅសាលាបឋមសិក្សាព្រះអង្គម្ចាស់ក្សត្រីនរោត្តម ម៉ារីណេឫទ្ធិស្តើងជ័យ ស្ថិតក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម និង
- អញ្ជើញដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ឯម ជា** ដែលត្រូវជាម្តាយក្មេករបស់ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា នៅគេហដ្ឋាននៃសព ស្ថិតក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភាបាន៖**

- អញ្ជើញចូលរួមពិធីថ្វាយព្រះពរជ័យសិរីមង្គល ក្នុងឱកាសចម្រើនព្រះជន្មវស្សានមង្គលគម្រប់ ៨៨ព្រះវស្សា យាងចូល ៨៩ព្រះវស្សា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ នៅព្រះបរមរាជវាំង។
- យាងដង្ហែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង**ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គទាំងទ្វេសព្វព្រះរាជហឫទ័យព្រះបរមរាជានុញ្ញាតព្រះរាជទាន ព្រះតេជព្រះគុណបណ្ឌិត KORI Shinkai នាយកប្រតិបត្តិ នៃនិកាយ Nenbutsushu វត្ត Sampozan Muryojuji ព្រមទាំងគណៈប្រតិភូ ចូលក្រាបថ្វាយបង្គំគាល់ ថ្វាយព្រះគោរមងារព្រះករុណាព្រះមហាក្សត្រ និងថ្វាយព្រះសព្ទសាធុការពរ ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តមវិសេសវិសាល នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៨ព្រះវស្សា យាងចូល ៨៩ព្រះវស្សា នៃសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះរាជដំណាក់សិរីមង្គល ក្នុងព្រះបរមរាជវាំង។
- អញ្ជើញចូលរួមដង្ហែ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា យាងចុះសួរសុខទុក្ខ និងព្រះប្រទានអំណោយដល់ប្រជាពលរដ្ឋជាអតីតយុទ្ធជន ចំនួន ៥០០គ្រួសារ នៅស្រុករមាសហែក ខេត្តស្វាយរៀង និងពិធីប្រគល់ផ្ទះ ចំនួន ១១៥ខ្នង ជូនដល់អតីតយុទ្ធជន ចំនួន ១១៥នាក់ នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។
- យាង និងអញ្ជើញចូលរួមក្នុងពិធីខួបគម្រប់២០ឆ្នាំ របស់អង្គការមូលនិធិកុមារកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ។
- យាងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ចូលរួមក្នុងពិធីមហាសន្និបាតលើកទី១១ សមាគមដូនជី និងឧបាសិកាកម្ពុជារង្គ នៅមណ្ឌលបណ្តុះបណ្តាលពុទ្ធសាសនិកនារី អតីតវត្តលោកកោះ ស្រុកពញាឮ ខេត្តកណ្តាល។

- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន ៥លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រួមមានៈ ពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការកំពង់ផែពហុបំណងកំពត របស់ក្រុមហ៊ុនកំពតផត, ពិធី " អ្នកស្នងមរតក " រក្សាចាស់ បង្កើត និងអភិវឌ្ឍន៍ថ្មី, ពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសភ្លោះ ត្រង់ចំណុចប្រសព្វមហាវិថី **សម្តេចតេជោ ហ៊ុន សែន** និងផ្លូវជាតិលេខ២, ពិធីសម្ពោធមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនា ព្រះធម្មចេតិយ តម្កល់ព្រះត្រៃបិដកចម្លាក់ថ្មម៉ាប ១,១៧០ផ្ទាំង ផ្លូវបេតុង ៩ខ្សែ បូជនីយដ្ឋានសមថៈវិបស្សនា និងសមិទ្ធផលនានា, ពិធីបុណ្យទីឃាយុវឌ្ឍនមង្គល ប្រោះព្រំព្រះសុគន្ធវារីថ្វាយ **សម្តេចព្រះមហាសុមេធាធិបតី កិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត** សម្តេចព្រះមហាសង្ឃរាជស្តីទី នៃព្រះរាជាណាចក្រកម្ពុជា គម្រប់ព្រះជន្ម ១០០ព្រះវស្សា យាងចូល ១០១ព្រះវស្សា នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តកំពត។
- អញ្ជើញចូលថ្វាយបង្គំ**សម្តេចព្រះពោធិវ័ង្ស កិត្តិបណ្ឌិត អ៊ំ លឹមហេង** សម្តេចព្រះសង្ឃនាយកស្តីទី គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តមុនីសុវណ្ណ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមកម្មវិធីប្រគល់ផ្ទះមនុស្សធម៌ទី១៩ ជូនប្រជាពលរដ្ឋទីទ័លក្រ ក្នុងស្រុកកងមាស ខេត្តកំពង់ចាម ដែលជាអំណោយរបស់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា។
- សព្វព្រះហឫទ័យយកអំណោយដ៏ថ្លៃថ្លាជាជំនួយរបស់ក្រុមហ៊ុន **ម៉ៅ ថាយ** ចែកជូនដល់ក្រុមគ្រួសារអ្នកជំងឺដែលមានជីវភាពខ្វះខាតកំពុងសម្រាកព្យាបាល ព្រមទាំងបុគ្គលិកមន្ត្រីបម្រើការ នៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ ចំនួន ១៥០នាក់។
- អញ្ជើញចុះពិនិត្យមើលវឌ្ឍនភាពនៃការជីកស្តារស្រះទឹក និងបានអញ្ជើញចូលរួមយុទ្ធនាការដាំដើមឈើប្រណិត ក្រោមប្រធានបទ "យុវជនក្រោមម្លប់សន្តិភាព" នៅវិទ្យាល័យស្វាយចេក វិទ្យាល័យជប់វារី វិទ្យាល័យហ៊ុន សែន ចារថ្មី និងក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។
- អញ្ជើញចូលរួមពិនិត្យសំណង់ទ្វារស្នាក់ទឹកប្រៃសម្រាប់តម្កល់ទឹកសាប និងបានជីកស្តារស្រះទឹកមួយកន្លែងទុកជូនប្រជាពលរដ្ឋប្រើប្រាស់ ព្រមទាំងអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខមន្ត្រី បុគ្គលិក នៅមណ្ឌលសុខភាពអង្កោល ដើម្បីឈ្វេងយល់អំពីការផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋ នៅស្រុកដំណាក់ចង្អើរ ខេត្តកែប។
- អញ្ជើញទទួលជួបជាមួយប្រជាកសិករដាំដំណាំត្រសក់ផ្អែម មកពីស្រុកសំឡូត ខេត្តបាត់ដំបង ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងសិក្សាលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម ព្រមទាំងទស្សនកិច្ចនៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ **ម៉ុង ឫទ្ធី** សែនជ័យ។
- អញ្ជើញចូលរួមសិក្ខាសាលាស្តីពី " កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ " របស់រាជរដ្ឋាភិបាលជូនតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា នៅសណ្ឋាគារសុខាភ្នំពេញ។

- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រី បុគ្គលិកកាកបាទក្រហមកម្ពុជា ទីស្នាក់ការកណ្តាល និងសាខារាជធានី-ខេត្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា។
- អញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួប១០ឆ្នាំ របស់បណ្ឌិត្យសភាបច្ចេកវិទ្យា ឌីជីថលកម្ពុជា (CADT) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា នៅបណ្ឌិត្យសភាបច្ចេកវិទ្យា ឌីជីថលកម្ពុជា។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រកាសចូលកាន់តំណែងរបស់ក្រុមប្រឹក្សាស្រុក នៅខេត្តព្រះសីហនុ និងខេត្តបន្ទាយមានជ័យ អាណត្តិទី៤។
- អញ្ជើញចូលរួមអបអរសាទរខួបទី១៦១ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៤ ក្រោមប្រធានបទ "រួមគ្នាជាមួយកាកបាទក្រហមកម្ពុជា ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ" នៅសាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ។
- អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកាព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣, ទី៤, ទី៦ និងទី៨ ដើម្បីពិនិត្យ និងពិភាក្សាលើការងារផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ, គោលការណ៍សំខាន់ៗ ដើម្បីអនុវត្តការងាររបស់ក្រុម, ផែនការយុទ្ធសាស្ត្ររយៈពេល៦ឆ្នាំ(២០២៤-២០៣០), ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ និងបញ្ហាផ្សេងៗ នៅវិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមជាវាគ្មិនធ្វើបទបង្ហាញចំនួន ២លើក ស្តីពី « បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា » និងស្តីពី « លក្ខន្តិកៈសមាជិកព្រឹទ្ធសភា អភ័យឯកសិទ្ធិ និងផលប្រយោជន៍របស់សមាជិកព្រឹទ្ធសភា និងក្រមសីលធម៌សមាជិកព្រឹទ្ធសភា » ជូនសមាជិក សមាជិកាព្រឹទ្ធសភា នីតិកាលទី៥ នៅសាលបណ្ណាល័យព្រឹទ្ធសភា។
- អញ្ជើញចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់អគ្គនាយកដ្ឋានស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើសេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី៩ ព្រឹទ្ធសភា។
- អញ្ជើញចូលរួមប្រារព្ធពិធីសូត្រមន្តចម្រើនព្រះបរិត្ត ស្តាប់ធម៌ទេសនា ក្នុងកម្មវិធីបុណ្យឆ្លងសមិទ្ធផលនានា នៅវត្តអង្គកែវឧត្តម ស្ថិតក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។
- អញ្ជើញចូលរួមពិធីបើក និងបិទការសូត្រលើកទី៣១ និងសូត្រចាំមាត់លើកទី៥ គម្ពីរអាល់គួរអានុការីម ថ្នាក់ជាតិឆ្នាំ២០២៤ នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៩ឆ្នាំ និងគម្រប់១៥ឆ្នាំ ឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាណក្ខន្ធ**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជា ស៊ីម** នៅវត្តមុនីប្រសិទ្ធីវង្ស ស្ថិតក្នុងខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

- អញ្ជើញចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធចំពោះវីរយុទ្ធជន វីរយុទ្ធនារី និងប្រជាជនកម្ពុជា ដែលបានពលីក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅមហាចេតិយតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្មX16 ស្ថិតនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្នុងឱកាសរំលឹកខួបលើកទី៤៧ នៃទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០ មិថុនា ១៩៧៧- ២០ មិថុនា ២០២៤។
- អញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ របស់ឯកឧត្តម **ឃួន ផល្លាវិទ្ធ** អតីតនាយករងខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា និងត្រូវជាប្អូនប្រុសរបស់សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តវិមានតេជះ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃ របស់ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **គង់ ម៉ាលី** ដែលត្រូវជាបងស្រីបង្កើតរបស់សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅគេហដ្ឋាននៃសព រាជធានីភ្នំពេញ។
- អញ្ជើញដាក់កូរោនផ្កា គោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ឯម ជា** ដែលត្រូវជាម្តាយក្មេករបស់ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា នៅគេហដ្ឋាននៃសព ស្ថិតក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមរំលែកទុក្ខជាមួយគ្រួសារសពកុមារី **អ៊ីន សុភ័ក្រ** ដែលបានបាត់បង់ជីវិតក្នុងឧបទ្ទវហេតុលិចទូកចម្លង នៅខេត្តកំពង់ធំ។

❖ ដោយឡែកសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការអភិវឌ្ឍមូលដ្ឋាន ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ ចុះពិនិត្យមើលវឌ្ឍនភាពនៃការជីកស្តារប្រព័ន្ធធារាសាស្ត្រ អញ្ជើញនាំយកថវិកា និងអំណោយគ្រឿងឧបភោគ បរិភោគ ជូនប្រជាពលរដ្ឋដែលកំពុងខ្វះខាត និងរងគ្រោះធម្មជាតិ ព្រមទាំងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន ៩៩លើក ព្រមទាំងបានអញ្ជើញជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ ចំនួន ១៣២លើក។

- ❖ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងគណៈប្រតិភូ បានអញ្ជើញនាំយកតង្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ថ្វាយ**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុគម្រប់ ៨៨ព្រះវស្សា យាងចូល ៨៩ព្រះវស្សា។
- ❖ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងផ្តល់អនុសាសន៍ដល់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលជាអ្នកគ្រប់គ្រងកម្រិតមធ្យម ចំនួន ២០នាក់ មុនពេលទៅចូលរួមបណ្តុះបណ្តាលស្តីពី គោលនយោបាយសាធារណៈ និងអភិបាលកិច្ចសម្រាប់មន្ត្រីរាជការកម្ពុជា នៅសាធារណរដ្ឋឥណ្ឌា។
- ❖ ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ និងជំនួបសំណេះសំណាល និងផ្តល់អនុសាសន៍រវាងឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជូនដល់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមក្នុងកម្មវិធីផ្សេងៗ នៅវិមានព្រឹទ្ធសភា ចំនួន ៤លើក និង
- ❖ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា និងគណៈប្រតិភូ បានអញ្ជើញចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធចំពោះវីរយុទ្ធជន វីរយុទ្ធនារី និងប្រជាជនកម្ពុជា ដែលបានពលីក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅមហាចេតិយតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្មX16 ស្ថិតនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្នុងឱកាសរំលឹកខួបលើកទី៤៧ នៃទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០ មិថុនា ១៩៧៧- ២០ មិថុនា ២០២៤។

- បានទទួលពាក្យបណ្តឹង ចំនួន ៥បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន ៥បណ្តឹង បានទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន ២បណ្តឹង។
- បានធ្វើបទបង្ហាញ ចំនួន ២លើក ស្តីពី "នីតិវិធីនៃការបង្កើតច្បាប់កម្ពុជា" និងស្តីពី " តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា" ជូនសាស្ត្រាចារ្យ បុគ្គលិក និងនិស្សិត នៃសាកលវិទ្យាល័យជាតិបាត់ដំបង និងវិទ្យាស្ថានវ៉ាន់ដា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្វាយព្រះពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្រាបបង្គំទូលថ្វាយ**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ក្នុងឱកាសប្រកបដោយមហាជ័យមង្គល វិបុលសុខបវរថ្លៃថ្លា មហាប្រសើរនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មរបស់សម្តេចព្រះមហាក្សត្រីគម្រប់ ៨៨ព្រះវស្សា យាងចូល ៨៩ព្រះវស្សា។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូនៈ
    - ឯកឧត្តម **ម៉ម ប៊ុននាង** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាព មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ឯម ជា** និង
    - សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីវង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាព ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **គង់ ម៉ាលី**។
- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភា ចំនួន ៣៥នាក់។

## ២-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាៈ
  - ❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអនុញ្ញាតឱ្យឥស្សរជនជាន់ខ្ពស់ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងគណៈប្រតិភូអន្តរជាតិនានា ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងជម្រាបលា ចំនួន ១៣លើកៈ
    - ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឥស្សរជនជាន់ខ្ពស់ និងគណៈប្រតិភូអន្តរជាតិនានា នៅវិមានព្រឹទ្ធសភា ចំនួន ២លើក នៅភូមិគ្រឹះ**សម្តេចតេជោ** ក្រុងតាខ្មៅ ចំនួន ១លើក និងតាមប្រព័ន្ធនិម្មិត ចំនួន ១លើក រួមមានៈ
        - ឯកឧត្តម **ឡយ ជេម អូស្ទីន** III (Loyd James Austin III) រដ្ឋមន្ត្រីការពារជាតិសហរដ្ឋអាមេរិក។
        - ឯកឧត្តម **ម៉ារីស សាងៀមផុង្សា** (Maris Sanggiampongsa) រដ្ឋមន្ត្រីការបរទេស នៃព្រះរាជាណាចក្រថៃឡង់ដ៏។
        - ឯកឧត្តម **វីលៀម ជេ ប៊ឺនស** (William J. Burns) នាយកទីភ្នាក់ងារស៊ើបការណ៍មជ្ឈិម (CIA) របស់សហរដ្ឋអាមេរិក នៅភូមិគ្រឹះ**សម្តេចតេជោ** ក្រុងតាខ្មៅ និង
        - ឯកឧត្តម **រូស្លាន ស្តេហ្វានឈុក** (Ruslan Stefanchuk) ប្រធានសភាអ៊ុយក្រែន តាមប្រព័ន្ធនិម្មិត នៅភូមិគ្រឹះ**សម្តេចតេជោ** ក្រុងតាខ្មៅ។

- ជំនួបសម្ដែងការគួរសម ពិភាក្សាការងារ និងជម្រាបលា ដោយឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាននៅរាជធានីភ្នំពេញ នៅវិមានព្រឹទ្ធសភា ចំនួន ៨លើក រួមមាន៖
  - ឯកឧត្ដម **វ៉ាង វិនជៀន** (Wang Wentian) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន។
  - ឯកឧត្ដម **ដូមីនីក វីល្លៀមស៍** (Dominic Williams) ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃចក្រភពអង់គ្លេស។
  - លោកជំទាវ **មីឡេនណា ការីដាដ ហ្សាឌីវ៉ា ពា្យេដ្រា** (Milena Caridad Zaldivar Piedra) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា។
  - ឯកឧត្ដម **សាន់តូ ដាម៉ូស៊ូម៉ាតូ** (Santo Darmosumarto) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា។
  - ឯកឧត្ដម **ផាក ជុងវុក** (Park Jung-Wook) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា។
  - ឯកឧត្ដម **អាណាតូលី បូរ៉ូវីក** (Anatoly Borovik) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា។
  - ឯកឧត្ដម **អ៊ីហ្គោរ៍ ទ្រីសម៉ាន់** (Igor Driesmans) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា និង
  - ឯកឧត្ដម **ស្សាហារ៉ូឌីន ប៊ីន អ៊ន** (Shaharuddin Bin Onn) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសម៉ាឡេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា។
- ជំនួបសម្ដែងការគួរសមជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាននៅក្រៅប្រទេស នៅវិមានព្រឹទ្ធសភា ចំនួន ១លើក គឺ ឯកឧត្ដម **ម៉ូហាមេដ អាប់ឌុល ហៃ** (Mohammed Abdul Hye) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា បានៈ

- អញ្ជើញចូលរួមក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជាមួយឯកឧត្តម **ឡយ ជេម អូស្ទីន III** ( Loyd James Austin III ) រដ្ឋមន្ត្រីការពារជាតិសហរដ្ឋអាមេរិក នៅវិមានព្រឹទ្ធសភា។
- អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា ចំនួន ២លើក រួមមានៈ
    - លោកជំទាវ Tiffany McDonald ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអូស្ត្រាលី ប្រចាំអាស៊ាន និង
    - លោកជំទាវ **មីឡេនណា ការីដាដ ហ្សាឌីវ៉ា ពាជ្រា** ( Milena Caridad Zaldivar Piedra ) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា។
- អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំ ដើម្បីត្រៀមលក្ខណៈចូលរួមមហាសន្និបាតលើកទី៤៩ នៃសភាប្រើភាសាបារាំង (APF-49) នៅប្រទេសកាណាដា នៅវិមានព្រឹទ្ធសភា ចំនួន២លើក។

❖ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី២ព្រឹទ្ធសភា បានៈ

- អញ្ជើញចូលរួមក្នុងជំនួបពិភាក្សាការងាររវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជាមួយឯកឧត្តម **រូស្លាន ស្តេហ្វានឈុក** ( Ruslan Stefanchuk ) ប្រធានសភាអ៊ុយក្រែន តាមប្រព័ន្ធនិម្មិត នៅភូមិគ្រឹះ**សម្តេចតេជោ** ក្រុងតាខ្មៅ។
- អញ្ជើញចូលរួមក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជាមួយឯកឧត្តម **ឡយ ជេម អូស្ទីន III** ( Loyd James Austin III ) រដ្ឋមន្ត្រីការពារជាតិសហរដ្ឋអាមេរិក នៅវិមានព្រឹទ្ធសភា។
- អនុញ្ញាតឱ្យលោក **គីម ជុងណាម** ( Kim Jung Nam ) ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ចូលជួបសម្តែងការគួរសម និងអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា( MOU ) រវាងគណៈកម្មការទី១០ព្រឹទ្ធសភា ជាមួយប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ស្តីពីកិច្ចព្រមព្រៀងផ្តល់មនុស្សធម៌ដល់ព្រឹទ្ធសភាកម្ពុជា នៅវិមានព្រឹទ្ធសភា។
- អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមគណៈប្រតិភូសភាកម្ពុជា ដើម្បីត្រៀមលក្ខណៈចូលរួមមហាសន្និបាតលើកទី៤៩ នៃសភាប្រើភាសាបារាំង( APF-49 ) នៅប្រទេសកាណាដា នៅវិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមកិច្ចប្រជុំ ដើម្បីត្រៀមលក្ខណៈចូលរួមជាមួយរដ្ឋសភាកម្ពុជា នៅក្នុងការរៀបចំសម័យប្រជុំពេញអង្គលើកទី១១ នៃសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព ( IPTP ) ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នាពេលខាងមុខនេះ នៅវិមានព្រឹទ្ធសភា។

- រៀបចំពិធីពិសាអាហារពេលល្ងាចជូនឯកឧត្តម **វ៉ាង វិនធៀន** (WANG Wentian) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលឯកឧត្តមឯកអគ្គរដ្ឋទូតនឹងត្រូវបញ្ចប់អាណត្តិបេសកកម្មការទូត នៅភោជនីយដ្ឋាន Topaz រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងក្នុងឱកាសនៃបុណ្យជាតិរបស់សហព័ន្ធរុស្ស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា និង
- អញ្ជើញចូលរួមជាកិត្តិយសពិសាអាហារមិត្តភាពជាមួយលោកស្រី **Bec Strating** សាស្ត្រាចារ្យមកពីនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃសាកលវិទ្យាល័យ La Trobe និងអ្នកសម្រួលផ្លូវសមុទ្រសម្រាប់កិច្ចប្រជុំកំពូល អូស្ត្រាលី អាស៊ាន នៅភោជនីយដ្ឋានក្រវ៉ាញ រាជធានីភ្នំពេញ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា បាន៖**

- អញ្ជើញចូលរួមកិច្ចប្រជុំតំបន់អាស៊ី-ប៉ាស៊ីហ្វិក នៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត នៅវិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមកិច្ចប្រជុំ ដើម្បីត្រៀមលក្ខណៈចូលរួមមហាសន្និបាតលើកទី៤៩ នៃសភាប្រើភាសាបារាំង (APF-49) នៅប្រទេសកាណាដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានគណៈប្រតិភូសភាកម្ពុជា នៅវិមានព្រឹទ្ធសភា និង
- អញ្ជើញចូលរួមកិច្ចប្រជុំត្រៀមរៀបចំសម័យប្រជុំពេញអង្គលើកទី១១ នៃសភាអន្តរជាតិដើម្បីភាពអត់ឱន និងសន្តិភាព (IPTP) ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នាពេលខាងមុខនេះ នៅវិមានព្រឹទ្ធសភា។

❖ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បាន៖

- អញ្ជើញចូលរួមវេទិកាក្រោមមូលបទ " ភាពជាដៃគូតំបន់ដើម្បីការអភិវឌ្ឍរួម (Regional Partnership for Common Development) " នៅសាធារណរដ្ឋប្រជាមានិតចិន និង
- អនុញ្ញាតឱ្យថ្នាក់ដឹកនាំសាកលវិទ្យាល័យអន្តរជាតិផាវ៉ាហ្គន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា។

❖ ឯកឧត្តមបណ្ឌិត **ប៉ែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បាន៖

- អញ្ជើញចូលរួមពិធីបើកសម្ពោធការិយាល័យអគ្គកុងស៊ុលអាល្លឺម៉ង់ និងចូលរួមពិធី Cocktail Reception តាមការអញ្ជើញរបស់លោក **Stefan Messerer** ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅភោជនីយដ្ឋានស្លាបព្រា នៅខេត្តសៀមរាប។

- អញ្ជើញចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្មស្តេច Charles III នៃចក្រភពអង់គ្លេស នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមពិធីគម្រប់ខួបលើកទី៥០ នៃទំនាក់ទំនងអាស៊ាន-អូស្ត្រាលី នៅនិវេសនដ្ឋានឯកអគ្គរដ្ឋទូតអូស្ត្រាលី រាជធានីភ្នំពេញ និង
- អញ្ជើញពិសាអាហារថ្ងៃត្រង់ និងពិភាក្សាការងារជាមួយឯកអគ្គរាជទូតជប៉ុន, ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋតួកគី ប្រចាំព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូអន្តរជាតិនានា នៅរាជធានីភ្នំពេញ ចំនួន ៣លើក។

❖ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បាន៖

- អញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍ និងជូនដំណើរ លោក **គីម ជុងណាម** (Kim Jung Nam) ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ និងគណៈប្រតិភូមកទស្សនកិច្ចការងារ នៅព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ព្រមទាំងបានរៀបចំពិធីពិសាអាហារ ជូនលោក **គីម ជុងណាម** (Kim Jung Nam) និងគណៈប្រតិភូ នៅភោជនីយដ្ឋានកូរ៉េ SOOKDAL ស្ថិតក្នុងរាជធានីភ្នំពេញ និង
- ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU)ជាមួយ លោក **គីម ជុងណាម** (Kim Jung Nam) ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ស្តីពី កិច្ចព្រមព្រៀងផ្តល់មនុស្សធម៌ដល់ព្រឹទ្ធសភាកម្ពុជា នៅវិមានព្រឹទ្ធសភា។

❖ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងលោក **គីម ជុងណាម** ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ និងគណៈប្រតិភូ អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តសៀមរាប និងបានអញ្ជើញទស្សនកិច្ចមជ្ឈមណ្ឌលកុមារកំព្រារដ្ឋខេត្តកំពង់ស្ពឺ និងមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ ព្រមទាំងទស្សនាប្រាសាទនានាក្នុងបរិវេណអង្គរវត្ត នៅខេត្តសៀមរាប។

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតសិង្ហបុរី, ស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេដារូហ្សាឡាម, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ស្ថានទូតវៀតណាម, ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT), វិទ្យាស្ថានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, វិទ្យាស្ថានសាន់វ៉ាយ, ក្រុមហ៊ុនកូហា, បណ្ណាល័យ និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៣-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៣.១-កិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា និងកម្មវិធីផ្សេងៗ៖

- ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំដើម្បីត្រៀមការងារបម្រើសេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា និងរដ្ឋសភា នៅវិមានរដ្ឋសភា។
- ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បាន៖
    - ប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលបណ្ណាល័យព្រឹទ្ធសភា
    - ដឹកនាំកិច្ចប្រជុំការងារជាមួយអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ និងនាយកដ្ឋានព័ត៌មាន នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា និង
    - ដឹកនាំកិច្ចប្រជុំស្តីពី ការអនុវត្តការរៀបចំផលិត និងបោះពុម្ពឯកសាររបស់ព្រឹទ្ធសភាប្រចាំឆ្នាំនីតិកាលទី៥ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។
- ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំការងារសំខាន់ៗ ដឹកនាំដោយឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា ចំនួន ៥លើក។
- ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញប្រជុំការងារសំខាន់ៗ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និង
- លោកជំទាវ **សួន ពុធថាវី** អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ បានធ្វើបទបង្ហាញស្តីពី "រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសមិទ្ធផលការងាររបស់នាយកដ្ឋានស្រាវជ្រាវថវិកា(PBO)" ជូនគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា នៅវិមានរដ្ឋសភា។

### ៣.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានរៀបចំបូកសរុបផែនការតម្រូវការសម្ភារៈ និងថវិកាប្រចាំឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានតាមដានអាណត្តិលេខ ០០៤៥ ជំពូក៦៤ ស្តីពី ប្រាក់បំណាច់ នាយក នាយករង ខុទ្ទកាល័យ ទីប្រឹក្សា ជំនួយការ ប្រចាំខែឧសភា និងខែមិថុនា ឆ្នាំ២០២៤។
- បានបើកប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារបន្ថែម ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺ ប្រាក់ឧបត្ថម្ភធ្វើដំណើរ និងសេវាទំនាក់ទំនងប្រចាំខែមិថុនា ឆ្នាំ២០២៤ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ភ្នាក់ងារសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត និងនិវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមរយៈធនាគារ។

- បានរៀបចំបង្វែរប្រាក់ឧបត្ថម្ភក្រុមយន្តការនានារបស់ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រចាំខែមិថុនា ឆ្នាំ២០២៤។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម(ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៤។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៧៩សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន ២០៣សំណើ។
- បានដោះស្រាយសំណើផ្សេងៗ និងផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ សម្ភារៈអនាម័យ សម្ភារៈការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា កម្មវិធីផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ២៧សំណើ។
- បានថតចម្លងឯកសារ ចំនួន ៧,១៨៩ច្បាប់ និងចងក្រងធ្វើជាសៀវភៅ ចំនួន ២១ក្បាល អស់ក្រដាសសរុបចំនួន ៥៦,៤០២សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តទាំង ៨ភូមិភាគ ចំនួន ៥៨លើក ស្មើនឹង ១៧៥នាក់។
- បានរៀបចំ បោសសម្អាត តុបតែងលម្អសាល តាំងលម្អផ្កាមុខអគារក្រហម និងសាលជំនួបភ្ញៀវ ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន ៤១លើក ស្មើនឹង ១៥០នាក់។
- បានទទួលលិខិតចូល ចំនួន ៣៧៧ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង ស្ថាប័នពាក់ព័ន្ធនានា ចំនួន ៣៤៥ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១១ច្បាប់ ស្មើនឹង ៥៥នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន ២ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តកំពង់ចាម ចំនួន ៩នាក់។
- បានផ្តល់ប័ណ្ណរថយន្តចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភា ឆ្នាំ២០២៤ ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ២៤សន្លឹក។

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន ១៣លើក ព្រមទាំងបានដាំស្មៅ និងផ្កាចម្រុះពណ៌នានា នៅសួនច្បារខាងមុខខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងអគារក្រហម ព្រឹទ្ធសភា ចំនួន ១០ប្លង់ និងបានដាំរុក្ខជាតិលម្អផ្សេងៗ នៅសួនបណ្តុះព្រឹទ្ធសភា ចំនួន ៣៤ផើង។
- បន្តយកចិត្តទុកដាក់ការងារអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីជានាឱ្យមានផាសុកភាព និងបរិស្ថាន បៃតង។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា រួមមាន៖
    - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន ៧០៣នាក់ (ប្រុស ៤១៧នាក់, ស្រី ២៨៦នាក់)
    - បុគ្គលិកជាប់កិច្ចសន្យា ចំនួន ៧៩នាក់ (ប្រុស ៤៦នាក់, ស្រី ៣៣នាក់)
    - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន ៤៩១នាក់ (ប្រុស ៣០៤នាក់, ស្រី ១៨៧នាក់) និង
    - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន ១០នាក់ និងព្យួរក្រៅក្របខ័ណ្ឌដើម ចំនួន ៣នាក់។
- បានធ្វើលិខិតបង្គាប់ការ និងសេចក្តីសម្រេចផ្សេងៗ ចំនួន ៩ច្បាប់។
- បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភា ជូនជំនួយការ និងទីប្រឹក្សា ចំនួន ២៣ប័ណ្ណ។
- បានធ្វើតារាងបញ្ជាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្គង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេល បំពេញការងាររដ្ឋ ចំនួន ៨ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែមិថុនា ឆ្នាំ២០២៤ (មន្ត្រីរាជការស្នើសុំបញ្ចូលប្រាក់ឧបត្ថម្ភសម្រាប់កូន ចំនួន ៥នាក់) ។
- បានទទួលលិខិតសុំអនុញ្ញាតច្បាប់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកត់ត្រា ចូលក្នុងសៀវភៅការងារ ចំនួន ៣៥ច្បាប់។
- បានបើកវគ្គបណ្តុះបណ្តាលក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន ២វគ្គ ស្តីពី " ភាសាចិនថ្នាក់បឋម " និង " ភាសាចិនថ្នាក់មធ្យម "។
- បានបញ្ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមវគ្គបណ្តុះបណ្តាល ចំនួន ៣វគ្គ៖
    - វគ្គ "ការព្យាករថវិកាដោយប្រើប្រាស់ម៉ូដែលម៉ាក្រូសេដ្ឋកិច្ច-ថវិកា" នៅមជ្ឈមណ្ឌល សភាអាស៊ី។
    - វគ្គ " ការទូតសភា" ជំហានទី៦ នៅមជ្ឈមណ្ឌលសភាអាស៊ី និង

- វគ្គ " ការប្រើប្រាស់ភាសាអង់គ្លេសសម្រាប់ចរចាប្រកបដោយប្រសិទ្ធភាព" នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី។

- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗរួមមាន៖
  - បានជួសជុលកែលម្អអគារខុទ្ទកាល័យ ការិយាល័យខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា គណៈកម្មការទី៦ព្រឹទ្ធសភា និងពង្រីកផ្នែកខាងលើសាលបណ្ណាល័យព្រឹទ្ធសភា
  - បានសាងសង់បន្ទប់ស្នាក់នៅរបស់នគរបាលនៅច្រកចេញ-ចូលព្រឹទ្ធសភា (P2) និង
  - បានស្តារប្រព័ន្ធលូ បាញ់លាងសម្អាតតាមដងផ្លូវក្នុងបរិវេណព្រឹទ្ធសភា។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី, ត្រួតពិនិត្យជណ្តើរយន្ត សត្វកណ្តៀរ, រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម, ប្រមូលសម្ភារៈខូច, បិទលេខកូដសម្ភារៈសារពើភណ្ឌ, ប្រគល់ និងបំពាក់សម្ភារៈការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន ៣៩៨គ្រឿង/លើក។
- បានចុះធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (ព្រឹទ្ធសភា)។
- បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាក ចំនួន ៤៦លើក។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៤ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៤។
- បានធ្វើរបាយការណ៍ និងសម្រង់ស្ថិតិស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៤ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង
- បានបញ្ចូលកាលប្បវត្តិស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាគណៈកម្មការជំនាញទាំង១០របស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៤ ក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន ១៥ច្បាប់។

**៣.៣-ការងារសេវាច្បាប់៖**

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្ដីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន ១១ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានចែក និងថ្វាយសេចក្ដីសម្រេចជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន ៣ច្បាប់ ស្ដីពី៖
  - ការបង្កើតក្រុមមិត្តភាពព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាជាមួយព្រឹទ្ធសភា-រដ្ឋសភា នៃបណ្ដាប្រទេសជាមិត្ត
  - ការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបន្ទុកសហប្រតិបត្តិការជាមួយអង្គការអន្តរសភា និង
  - ការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ត្រៀមសហការ និងចូលរួមជាមួយរដ្ឋសភាក្នុងកិច្ចប្រជុំនៃអង្គការអន្តរសភា។
- បានធ្វើកំណត់បង្ហាញ និងធ្វើសេចក្ដីជូនដំណឹងស្ដីពី ការបិទសម័យប្រជុំលើកទី១ ព្រឹទ្ធសភា នីតិកាលទី៥ និងប្រតិទិនសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥។
- បានធ្វើកំណត់បង្ហាញអំពីការបែងចែកភារកិច្ចក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ នីតិកាលទី៥ ត្រូវចុះបំពេញការងារតាមរាជធានី ខេត្ត។
- បានរៀបចំសេចក្ដីព្រាងស្ដីពី៖
  - របាយការណ៍សង្ខេបស្ដីពី លទ្ធផលការងារអនុវត្តមុខងារតំណាង ក្នុងនីតិកាលទី៤ និងទិសដៅ នីតិកាលទី៥ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា។
  - ឯកសារគ្រោងកម្មវិធីសម្រាប់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ចូលរួមពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ នៅភូមិភាគទី៣ ខេត្តកណ្ដាល និង
  - តារាងផែនការសកម្មភាពប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា។
- បានធ្វើសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១, ទី២, ទី៤, ទី៥, ទី៧ និងទី៨ និង
- បានតាមដានដំណើរការវិវឌ្ឍន៍សម័យប្រជុំរបស់រដ្ឋសភា។

**៣.៤-ការងារស្រាវជ្រាវ៖**

- បានសិក្សាស្រាវជ្រាវ និងផ្ដល់ឯកសារលើសេចក្ដីព្រាងច្បាប់ស្ដីពី ការរៀបចំដែនដី និងនគរូបនីយកម្ម ជូនសមាជិក សមាជិកាព្រឹទ្ធសភា។

- បានសិក្សាស្រាវជ្រាវ និងកសាងជំនួយស្មារតីស្តីពី វឌ្ឍនភាព នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅព្រះរាជាណាចក្រកម្ពុជា។
- បានតាមដាន និងសិក្សាស្រាវជ្រាវលើការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ។
- កំពុងសិក្សាស្រាវជ្រាវកសាងឯកសារជំនួយស្មារតីពាក់ព័ន្ធនឹងការលើកកម្ពស់អាជីវកម្មលក់រាយ និងអាជីវកម្មខ្នាតតូច និងមធ្យម។
- បានសិក្សាស្រាវជ្រាវ និងធ្វើសំយោគឯកសារព័ត៌មាន និងសង្ខេបខ្លឹមសារពាក់ព័ន្ធនឹងវិស័យនានា ចំនួន ១៨អត្ថបទ។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍ក្នុងខែមិថុនា ឆ្នាំ២០២៤ ចំនួន ៤ច្បាប់។
- បានស្រង់ឯកសារពីក្នុងរាជកិច្ច និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៣៦ -៤៥ ឆ្នាំ២០២៣) និង
- បានបញ្ចូលទិន្នន័យ (Database) ស្តីពី ថវិកាចំណូល-ចំណាយ ក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ច សម្រាប់ឆ្នាំ២០២៤ (TOFE) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៣.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន ២០លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងសកម្មភាពការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធ Facebook, Instagram, X (Former Twitter), Youtube និងTiktok ចំនួន ៨៩៧លើក។
- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន ១៤៤ប្រធានបទ។
- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃ ចំនួន ១,៧០៤ ប្រធានបទ។
- បានប្រមូល និងសង្ខេបព័ត៌មានជាតិ និងអន្តរជាតិ ជូនអ្នកនាំពាក្យព្រឹទ្ធសភា ចំនួន ១,៧០៧អត្ថបទ។

- បានអញ្ជើញអ្នកព័ត៌មានទូរទស្សន៍ជាតិកម្ពុជាចូលយកព័ត៌មានក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកម្មវិធីផ្សេងៗ ចំនួន ១៤លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅក្នុងសាលបណ្ណាល័យព្រឹទ្ធសភា និងខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន ១៣លើក។
- បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែមិថុនា ឆ្នាំ២០២៤ ចំនួន ៨០០ក្បាល។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត, ពង្រឹងពង្រីកការផ្គត់ផ្គង់ និងជួសជុលឧបករណ៍ សម្ភារៈ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន ៤៧គ្រឿង/លើក។
- បានបំពាក់ឧបករណ៍អេឡិចត្រូនិចជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៤គ្រឿង។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធសំឡេង ប្រព័ន្ធមេក្រូហ្វូន ប្រព័ន្ធរូបភាព ប្រព័ន្ធកាមេរ៉ា និងប្រព័ន្ធប្រជុំនិម្មិត ឬប្រព័ន្ធប្រជុំពីចម្ងាយ( Digital ) ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន ៤៧លើក។
- បានរៀបចំកម្មវិធីទទួលពាក្យបណ្តឹងព្រឹទ្ធសភាអេឡិចត្រូនិច ( Mobile Application ) និងយុទ្ធសាស្ត្រផ្សព្វផ្សាយ ។
- បានរៀបចំបំប្លែងកាសែតវីដេអូចាស់ៗរបស់ព្រឹទ្ធសភា ទៅជាប្រភេទវីដេអូឌីជីថល ដើម្បីរក្សាទុកក្នុងប្រព័ន្ធទិន្នន័យ។
- បានធ្វើបច្ចុប្បន្នភាពគេហទំព័រព្រឹទ្ធសភា នីតិកាលទី៥។
- បានទទួលឯកសារ ទស្សនាវដ្តី ព្រឹត្តិបត្រ សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន ១៤១ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ ដាក់លេខកូដសៀវភៅ អ៊ុតក្របសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន ៣៧៨ក្បាល។
- បានរៀបចំបញ្ចូលទិន្នន័យឯកសារ និងសៀវភៅក្នុងកម្មវិធីកូហា ចំនួន ២៥៦ក្បាល។
- បានផ្សព្វផ្សាយឯកសារ និងសៀវភៅដែលមាននៅក្នុងបណ្ណាល័យព្រឹទ្ធសភា ក្នុងផេកTikTok របស់បណ្ណាល័យព្រឹទ្ធសភា ( មានអ្នក Followers ចំនួន ៥៧នាក់ និងអ្នក Like ចំនួន ២០, ៣០០នាក់ ) និង
- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន សភាបៃតង សភាឌីជីថល រដ្ឋបាលអេឡិចត្រូនិច ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភា និងពិធីផ្សេងៗឱ្យបានលឿន ល្អ និងរលូន។

**៣.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន ៤៨លើក។
- បានរៀបចំសារលិខិតថ្វាយព្រះពរ លិខិតរំលែកទុក្ខ និងលិខិតអបអរសាទរ ទូលថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និងឥស្សរជនជាន់ខ្ពស់ ព្រមទាំងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ចំនួន ៤លិខិត។
- បានរៀបចំលិខិតថ្លែងអំណរគុណរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់នៃបណ្តាប្រទេសជាមិត្ត ចំនួន ១លើក។
- បានបកប្រែឯកសារនានា ចំនួន ៣ច្បាប់។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូតថ្មីជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៤០នាក់។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែមិថុនា ឆ្នាំ២០២៤ ចំនួន ១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ០៨ច្បាប់ និង
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌នៅខាងមុខស្ថាប័នព្រឹទ្ធសភា និងធ្វើហ្វុងអក្សរ ចងបដា ពាក្យស្លោក ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ។

**៣.៧-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៤ ចំនួន ២២លើក។
- បានប្រជុំពិភាក្សាការងារជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋាន ព្រមទាំងបានធ្វើរបាយការណ៍ស្តីពីការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែមិថុនា ឆ្នាំ២០២៤។
- បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ចំនួន ២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ។

- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន ៣៨លើក ប្រចាំសប្តាហ៍ ចំនួន ៤លើក និងប្រចាំខែមិថុនា ឆ្នាំ២០២៤។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែកក្កដា ឆ្នាំ២០២៤

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ជាបន្តបន្ទាប់ និង
- ខុទ្ទកាល័យថ្នាក់ដឹកនាំទាំង៣ លេខាធិការដ្ឋានអមគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមសមាជិកាព្រឹទ្ធសភា ត្រៀមធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភាចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៥ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយក្រសួង ស្ថាប័ន មន្ទីរ និងការចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា និង
- ត្រៀមផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះបំពេញការងារនៅមូលដ្ឋានក្នុងរយៈពេលវិស្សមកាល ៣ខែ (ចាប់ពីខែកក្កដា ដល់ ខែតុលា ឆ្នាំ២០២៤)។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ចុះពិនិត្យវឌ្ឍនភាព នៃការអភិវឌ្ឍ នៅថ្នាក់ក្រោមជាតិ ចូលរួមពិធីសាសនា និងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។
- ត្រៀមរៀបចំជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងទី៤ ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប និង
- ត្រៀមរៀបចំជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ និងទី៧ ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋ និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តតាកែវ ខេត្តកំពត និងខេត្តព្រះសីហនុ។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ផ្ដល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញចូលរួមៈ
  - មហាសន្និបាត លើកទី៤៩ នៃសភាប្រើភាសាបារាំង(APF-49) នៅប្រទេសកាណាដា នាខែកក្កដា ឆ្នាំ២០២៤ និង
  - ប្រជុំពេញអង្គលើកទី១១ នៃសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព (IPTP) ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នាខែវិច្ឆិកា ឆ្នាំ២០២៤។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការងារសាងសង់ ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- ត្រៀមផ្ដល់សេវាផ្គត់ផ្គង់សម្ភារៈ ថវិកា មធ្យោបាយដឹកជញ្ជូន និងសេវាសំខាន់ៗផ្សេងទៀត ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនបានទាន់ពេលវេលា និងល្អប្រសើរ។
- ត្រៀមបញ្ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមសិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលនានាៈ
  - សិក្ខាសាលា ចំនួន ២លើកស្ដីពី " ផែនការ និងសមត្ថភាពក្នុងការកសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍" និងស្ដីពី "សេដ្ឋកិច្ចបើកចំហសម្រាប់បណ្ដាប្រទេសដែលមានគំនិតផ្ដួចផ្ដើមខ្សែក្រវាត់ និងផ្លូវ" នៅសាធារណរដ្ឋប្រជាមានិតចិន និង
  - វគ្គបណ្ដុះបណ្ដាលស្ដីពី " ការកត់ត្រា និងសរសេររបាយការណ៍" នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី។
- ត្រៀមបើកវគ្គបណ្ដុះបណ្ដាលស្ដីពី " ជំនាញភាសាអង់គ្លេស និងទំនាក់ទំនងកម្រិតមធ្យម "។
- ត្រៀមធ្វើរបាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការប្រតិបត្តិរបស់នាយកដ្ឋានចំណុះអគ្គនាយកទាំង៥ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី២ ឆ្នាំ២០២៤ និង
- ត្រៀមចាត់ចែងការងារគ្រប់ផ្នែក គ្រប់វិស័យ តាមបរិបទថ្មីនៃព្រឹទ្ធសភា នីតិកាលទី៥។

III-**សេចក្តីសន្និដ្ឋាន**

ខែមិថុនានេះ ជាខែទីបី នៃការចាប់ផ្តើមនីតិកាលទី៥ របស់ព្រឹទ្ធសភា ការងារអាទិភាពធំពីរគឺ ការទូតសភា និងមុខងារតំណាង មានការមមាញឹក និងមានកំណើនជាលំដាប់ ហើយសម្រេចបាន លទ្ធផលជាច្រើន ប្រកបដោយគុណប្រយោជន៍សម្រាប់ជាតិ និងប្រជាជន។

ក្នុងបរិបទនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវបន្តលើកកម្ពស់ការផ្តល់សេវាតាមស្មារតី បុរេសកម្ម នវានុវត្តន៍ការងារ ពិពិធកម្មសេវា សាមគ្គីភាព គណនេយ្យភាព និងការគោរពវិន័យ ដើម្បីជានាកំណើនវឌ្ឍនភាពការងាររបស់ស្ថាប័នឱ្យកាន់តែល្អប្រសើរថែមមួយកម្រិតទៀត។

គ្រប់អង្គភាពត្រូវបន្តចូលរួមថែរក្សា សន្តិសុខ សុវត្ថិភាព របៀបរៀបរយ និងសណ្តាប់ធ្នាប់ឱ្យបានល្អ។

ថ្ងៃសុក្រ ២ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

**ឡាយ សំកុល**